# ការប្រែប្រួលនៃជំនួយសំរាប់ជនដែលមានការផ្តន្ទាទោសបទឧក្រិដ្ឋថ្នាំញៀនពីអតីតកាល ៖

ចាប់ពីថ្ងៃទី1ខែមេសា 2015 កម្មវិធី CalWORKs និងកម្មវិធី CalFresh នឹងអនុញ្ញាតឲ្យជនដែលមានការផ្តន្ទាទោសបទឧក្រិដ្ឋថ្នាំញៀនពីអតីតកាលអាចទទួលជំនួយបាន ។ នេះគឺមានន័យថាជនដែលត្រូវបានគេបដិសេធ ឬក៏ត្រូវបាត់បង់ជំនួយដោយសារតែមានការផ្តន្ទាទោសអ្វីមួយជននោះអាចទទួលជំនួយបានច្រើន ។ ឪពុក/ម្តាយនឹងត្រូវគេដាក់បញ្ចូលទៅក្នុងក្រុមជំនួយ (Assistance Unit - AU) នៃកម្មវិធី CalWORKs ស្វ័យប្រវត្តិ ។ ខោនធីនឹងប្រាប់អ្នកឲ្យដឹង បើគេត្រូវការព័ត៌មានពីអ្នកថែមទៀតដើម្បីគិតគូរដំណើរការឲ្យជននេះទទួលជំនួយ ។

ឪពុក/ម្តាយចុងដែលជាជម្រើស ហើយដែលមិនទាន់ជាផ្នែកនៃក្រុមជំនួយ (AU) របស់អ្នកនៅឡើយប្រហែលអាចបញ្ចូលបាន តែលោកអ្នកនឹងត្រូវទាក់ទងមកខោនធីបើសិនជាលោកអ្នកចង់បានជំនួយនោះសំរាប់ឪពុក/ម្តាយណាមួយ ឬសំរាប់ដៃគូចុះឈ្មោះជាដៃគូរគ្រួសារ ។

វាដូចជាមនុស្សដទៃទៀតដែលទទួលជំនួយពីកម្មវិធី CalWORKs និងកម្មវិធី CalFresh ជនដែលមានការផ្តន្ទាទោសឧក្រិដ្ឋកម្មថ្នាំញៀនដែលនៅក្នុងការដោះលែងមានល័ក្ខខ័ណ្ឌ ឬការព្យួរទោសមានល័ក្ខខ័ណ្ឌត្រូវតែធ្វើតាមវិធាននៃការដោះលែងមានល័ក្ខខ័ណ្ឌ និងការព្យួរទោសដោយមានល័ក្ខខ័ណ្ឌ រួមទាំងការព្យាបាលថ្នាំញៀនដែលមានការយល់ព្រម បើសិនជាការព្យាបាលនោះជាផ្នែកនៃការដោះលែង ឬការព្យួរទោសមានល័ក្ខខ័ណ្ឌរបស់ជននោះ ។

**លោកអ្នកនឹងទទួលសេចក្តីជូនដំណឹងនៃចំណាត់ការ ក្នុងខែមិនាបង្ហាញពីចំនួននៃប្រាក់ជំនួយរបស់លោកអ្នកដែលនឹងចាប់ផ្តើមនៅថ្ងៃទី 1 ខែមេសា ។**

---

## ការប្រែប្រួលក្នុងកម្មវិធី CalFresh ៖

ការបញ្ចូលមនុស្សម្នាក់ទៅក្នុងក្រុមគ្រួសាររបស់កម្មវិធី CalFresh ជាទូទៅគឺផ្តល់ជំនួយអាហារដល់អ្នកបានច្រើន ។ បើសិនជាជននោះក៏ត្រូវបញ្ចូលទៅក្នុងកម្មវិធី CalWORKs ដែរនោះ ហើយប្រាក់ជំនួយលោកអ្នកត្រូវកើនឡើង នោះជំនួយពីកម្មវិធី CalFresh ប្រហែលជានឹងត្រូវថយចុះ ។ **លោកអ្នកនឹងទទួលសេចក្តីជូនដំណឹងដោយឡែកពីគ្នា បើសិនជាជំនួយពីកម្មវិធី CalFresh របស់លោកអ្នកត្រូវប្រែប្រួល ។**

---

## កម្មវិធី Welfare-to-Work ៖

ការបញ្ចូលមនុស្សធំម្នាក់ទៅក្នុងកម្មវិធី CalWORKs អាចប្រែប្រួលដល់តំរូវការការងារសំរាប់គ្រួសារ ។ មនុស្សធំទទួលជំនួយប្រាក់ត្រូវតែធ្វើការ ឬធ្វើសកម្មភាពនានាដែលអាចនាំឲ្យមានការងារធ្វើ ។ មនុស្សខ្លះប្រហែលអាចត្រូវលើកលែង(អនុគ្រោះ) ពីតំរូវការការងារ ។ ជនដែលមានការផ្តន្ទាទោសឧក្រិដ្ឋកម្មថ្នាំញៀនពីអតីតកាលបានបញ្ចូលទៅក្នុងក្រុមជំនួយ AU របស់លោកអ្នកចាប់ផ្តើមពីថ្ងៃទី 1 ខែមេសា 2015 ប្រហែលនឹងតំរូវឲ្យចូលរួមក្នុងកម្មវិធី Welfare-to-Work (WTW) ។ មនុស្សដែលមិនតំរូវឲ្យចូលរួមក្នុងកម្មវិធី WTW តែគេអាចស្ម័គ្រចិត្តបាន ។

កម្មវិធី WTW អាចផ្តល់ការអប់រំ, ការហ្វឹកហ្វឺន, និងជំនាញការងារដើម្បីជួយលោកអ្នកស្វែងរកការងារធ្វើ។ ខោនធីនឹងជួយសម្រួលលោកអ្នកក្នុងការងារ នឹងជួយបង់ថ្លៃសំរាប់សេវាមើលថែទាំក្មេងដែរ ។ លោកអ្នកក៏នឹងមានការជួយចេញថ្លៃសំរាប់ការដឹកនាំ និងថ្លៃចំណាយផ្សេងៗដូចជាឧបករណ៍ពិសេសសំរាប់ការងារ និងសំលៀកបំពាក់ជាដើម ដែលលោកអ្នកត្រូវការសំរាប់ការងារ ឬចូលរួមក្នុងកម្មវិធី WTW របស់លោកអ្នក ។ បើសិនជាគ្រួសាររបស់លោកអ្នកបិតក្នុងវិបត្តិដូចជាគ្មានផ្ទះសម្បែង ឬមានបញ្ហាក្នុងគ្រួសារ កម្មវិធី CalWORKs ប្រហែលអាចផ្តល់សេវាពិសេសៗជូនលោកអ្នកបាន ។

បើសិនជាលោកអ្នកត្រូវ តំរូវឲ្យធ្វើ WTW ហើយលោកអ្នកមិនធ្វើតាមកិច្ចការដែលបានតំរូវ នោះជំនួយប្រាក់របស់លោកអ្នកប្រហែលអាចត្រូវបន្ថយ ។ ខោនធីនឹងផ្ញើព័ត៌មានច្រើនថែមទៀតជូនលោកអ្នកអំពីតំរូវការការងារនៃកម្មវិធី CalWORKs ។ គេនឹងផ្ញើទម្រង់ជូនលោកអ្នកដើម្បីស្នើសុំការលើកលែងពីតំរូវការនៃកម្មវិធី WTW ។

---

## ការមើលថែទាំកុមារ ៖

មនុស្សធំ ដែលទទួលជំនួយពីកម្មវិធី CalWORKs អាចទទួលសេវាជួយមើលថែទាំកុមារ បើសិនជាពួកគេធ្វើការ ឬធ្វើសកម្មភាព WTW ដែលមានការអនុញ្ញាត ។ បើសិនជាកូនរបស់លោកអ្នកបច្ចុប្បន្ននេះទទួលសេវាមើលថែទាំកុមារ ហើយលោកអ្នកចាប់ផ្តើមទទួលជំនួយពីកម្មវិធី CalWORKs លោកអ្នកមិនចាំបាច់ផ្លាស់ប្តូរអ្នកផ្តល់ការបំរើមើលថែទាំកុមារទេ ជាពិសេសបើអ្នកផ្តល់ការបំរើនេះ ទទួលយកប្រាក់បង់សំរាប់ការមើលថែទាំក្មេងពីកម្មវិធី CalWORKs ។

**ទាក់ទងមកខោនធីដើម្បីពិភាក្សាអំពីលទ្ធភាពជម្រើសនៃសេវាមើលថែទាំកុមារដែលលោកអ្នកប្រហែលមានសិទ្ធិទទួល ។**

---

## ការឧបត្ថម្ភកុមារ ៖

មនុស្សធំដែលទទួលជំនួយពីកម្មវិធី CalWORKs ត្រូវតែធ្វើសហការជាមួយនឹងសេវាទាមទារប្រាក់ឧបត្ថម្ភកុមារសំរាប់កូនៗដែលនៅក្នុងកម្មវិធី CalWORKs ។ ប្រាក់ឧបត្ថម្ភកុមារដែលទារបានត្រូវតែបង់សងទៅឲ្យខោនធីវិញ ។ នេះគឺមានន័យថា កាលណាសំណុំរឿងរបស់លោកអ្នកត្រូវគេបញ្ជូនទៅសេវាផ្នែកឧបត្ថម្ភកុមារ លោកអ្នកនឹងទទួលប្រាក់ជាអតិបរិមាគឺ $50 ក្នុងមួយខែជាប្រាក់ឧបត្ថម្ភកុមារ ។ ប្រាក់ $50 នឹងមិនរាប់ទល់នឹងប្រាក់ជំនួយរបស់លោកអ្នកទេ ។ ប្រាក់ឧបត្ថម្ភកុមារនៅសល់ទាំងប៉ុន្មានគឺត្រូវប្រើសំរាប់បង់សងទៅជំនួយប្រាក់របស់លោកអ្នក ។

**សូមទាក់ទងមកខោនធី បើសិនជាលោកអ្នកមានសំនួរអំពីការប្រែប្រួលក្នុងសេវាឧបត្ថម្ភកុមាររបស់លោកអ្នក ឬបើសិនជាគ្រួសារលោកអ្នកនឹងងាយក្នុងការរងគ្រោះ បើសិនគេទារប្រាក់ឧបត្ថម្ភកុមារ ។**